ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៥០៣...សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៤

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង

## ដើម្បីអនុវត្តប្រកាសអន្តរក្រសួង ស្តីពីភារកិច្ចធានារ៉ាប់រង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- **បានឃើញលិខិតរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន លេខ ៦៣១ សក.បធ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញលិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ លេខ ៦៨១ ដនស/បុ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤
- បានឃើញលិខិតរបស់ក្រសួងទេសចរណ៍ លេខ ១១៤ សជណ.អទច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤
- បានឃើញលិខិតរបស់ក្រសួងមហាផ្ទៃ លេខ ១២៧៩ សជណ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤
- យោងតាមការងារចាំបាច់នៃការងារគ្រប់គ្រងក្នុងការអនុវត្តប្រកាសអន្តរក្រសួងស្តីពីការជានាភ័ប់រង

**សម្រេច**

**ប្រការ ១.** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីពង្រឹងការអនុវត្តប្រកាសអន្តរក្រសួង ស្តីពីកាតព្វកិច្ចធានា-រ៉ាប់រង ។

**ប្រការ ២.** ក្រុមការងារអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **ឡៅ និព្វសីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤. លោក **សុខ ស៊ីចាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. លោក **ថ្នាក់ ច័ន្ទតារា** | អគ្គនាយករងទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៦. លោក **ឆាយ រតនៈ** | ប្រធាននាយកដ្ឋានធានារ៉ាប់រង និង សោធន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៧. លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៨ ឯកឧត្តមឧត្តមសេនីយ៍ទោ **ហ៊ឹមយ៉ាន** | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩ ឯកឧត្តមឧត្តមសេនីយ៍ត្រី **ជុំ ហេង** | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| ១០.លោកស្រី **ហោ សុខឡូនា** | អនុប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១១.លោក **ឌុយ ច័ន្ទដារ៉ា** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក<br>នៃអគ្គនាយកដ្ឋានដឹកជញ្ជូន<br>ក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១២.លោក **ឆុំ សុខណ្ណា** | ប្រធានការិយាល័យទ្រព្យ<br>នៃនាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ<br>អគ្គនាយកដ្ឋានរដ្ឋបាល<br>ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣.លោកស្រី **ហៃ សុមាលា** | ប្រធានការិយាល័យនីតិកម្ម និងផ្សះផ្សាវិវាទ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤.លោកស្រី **ម៉ាន់ សុលីដា** | ប្រធានការិយាល័យអភិវឌ្ឍន៍ទីផ្សារ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | លេខាកត់ត្រា |

**ប្រការ ៣.** ក្រុមការងារអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម÷

- អនុវត្តឱ្យបានត្រឹមត្រូវ និងម៉ត់ចត់នូវប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង
- ត្រួតពិនិត្យលតាបត្រធានារ៉ាប់រងឱ្យបានម៉ត់ចត់លើកញ្ចក់យានយន្ត ឬគ្រឿងចក្រទាំងឡាយណាដែលត្រូវអនុវត្តកាតព្វកិច្ចធានារ៉ាប់រង ដើម្បីរកឱ្យឃើញនូវយានយន្តទាំងឡាយដែលមិនអនុវត្តកាតព្វកិច្ចធានារ៉ាប់រង
- ធ្វើអធិការកិច្ចជាទៀងទាត់ចំពោះឯកសាររបស់ម្ចាស់ ឬប្រតិបត្តិករទាំងអស់ ដោយទាមទាររកឯកសារធានារ៉ាប់រងដែលមានសុពលភាព និងធ្វើការអប់រំដល់ប្រជាជន និងម្ចាស់ ឬប្រតិបត្តិករទាំងអស់ដែលពាក់ព័ន្ធទៅនឹងកាតព្វកិច្ចធានារ៉ាប់រង ឱ្យយល់ច្បាស់អំពីកាតព្វកិច្ចធានារ៉ាប់រង ភារៈទទួលខុសត្រូវយានយន្ត កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ដោយតម្រូវឱ្យភ្នាក់ងារទេសចរណ៍ទាំងអស់ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនណាដែលបានទិញធានារ៉ាប់រងតែប៉ុណ្ណោះ
- ធ្វើការដាក់ពិន័យដល់យានយន្តទាំងឡាយណាដែលមិនបានទិញធានារ៉ាប់រង និងណែនាំឱ្យម្ចាស់ និងប្រតិបត្តិករទិញធានារ៉ាប់រងក្នុងរយៈពេល ៧ថ្ងៃ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការណែនាំទេ ត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប័ណ្ណបើកបរ ឬ ត្រូវឃាត់យានយន្តទុកជាបណ្តោះអាសន្នមិនឱ្យធ្វើចរាចរណ៍ រហូតដល់ម្ចាស់យានយន្តបានទិញការធានារ៉ាប់រង

- ធ្វើការត្រួតពិនិត្យដោយផ្ទាល់ដល់ការដ្ឋានសំណង់ដើម្បីសួររកវិញ្ញាបនបត្រធានារ៉ាប់រង ។ ក្នុងករណីពុំមានវិញ្ញាបនបត្រធានារ៉ាប់រងទេ ត្រូវបញ្ឈប់សកម្មភាពការដ្ឋាននោះជាបណ្តោះអាសន្ន ហើយតម្រូវឱ្យទិញធានារ៉ាប់រង
- ចុះត្រួតពិនិត្យក្រុមហ៊ុនអាជីវកម្មដឹកជញ្ជូនគ្រប់ប្រភេទដែលពាក់ព័ន្ធទៅនឹងកាតព្វកិច្ចធានារ៉ាប់រង
- ជម្រុញការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួងពាក់ព័ន្ធបានចេញឱ្យប្រើប្រាស់កន្លងមក
- ធ្វើការផ្សព្វផ្សាយជូនសាធារណជន និងក្រុមហ៊ុនឯកជននៅតាមបណ្តាខេត្ត-ក្រុងឱ្យយល់អំពីកាតព្វកិច្ចធានារ៉ាប់រង ដោយរៀបចំជាសិក្ខាសាលាផ្សេងៗ
- ក្រុមការងារមកពីក្រសួងពាក់ព័ន្ធត្រូវផ្ញើនូវរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ អំពីយានយន្ត និងការដ្ឋានសំណង់ជាប់ជាកាតព្វកិច្ច មកលេខាធិការដ្ឋាន ។

**ប្រការ ៤.** នាយកដ្ឋានធានារ៉ាប់រង និង សោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងនេះ ។

**ប្រការ ៥.** ប្រធានក្រុមការងារអន្តរក្រសួង មានសិទ្ធិអញ្ជើញសមាជិកក្រុមការងារអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៦.** ប្រកាសលេខ១២៨ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.** នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងនៅក្នុងប្រការ ២ នៃប្រកាសនេះ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ [illegible]

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ